**សម្តេចពិជ័យសេនា ទៀ បាញ់**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សាររំលែកទុក្ខ

## ជូន

## ឯកឧត្តម នាយឧត្តមសេនីយ៍ ម៉ក់ សារុន និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ

**ឯកឧត្តម នាយឧត្តមសេនីយ៍ និងលោកជំទាវ ជាទីរាប់អាន!**

ខ្ញុំនិងភរិយា មានក្តីរំជួលចិត្តឥតឧបមាដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា **ឧបាសិកា ស្រី អឿន** ត្រូវជាម្តាយបង្កើតរបស់ឯកឧត្តម **នាយឧត្តមសេនីយ៍** បានទទួលមរណភាពកាលពីថ្ងៃអាទិត្យ ៨កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២២ ក្នុងជន្មាយុ៩០ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយសមានទុក្ខនេះ ខ្ញុំនិងភរិយាសូមសម្តែងនូវការសោកស្តាយ ស្រណោះអាឡោះអាល័យជាទីបំផុតជាមួយក្រុមគ្រួសារនៃសព ព្រោះការបាត់បង់ឧបាសិកា **ស្រី អឿន** គឺជាការបាត់បង់នូវម្តាយ ដ៏ដូន ដ៏ទួត ប្រកបដោយព្រហ្មវិហារធម៌ល្អប្រពៃចំពោះកូនចៅជាទីស្រលាញ់។

ខ្ញុំនិងភរិយា សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធសព**ឧបាសិកា ស្រី អឿន** សូមឆាប់បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តម នាយឧត្តមសេនីយ៍ និងលោកជំទាវ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**